## ក្រមព្រហ្មទណ្ឌកាលីហ្វញ៉ា ផ្នែក 148.6

លោកអ្នកមានសិទ្ធិដាក់ពាក្យបណ្តឹង ដល់មន្រ្តីនគរបាល សម្រាប់ការប្រតិបត្តិ មិនត្រឹមត្រូវណាមួយបាន៖ ច្បាប់របស់កាលីហ្វញ៉ា តម្រូវឱ្យភ្នាក់ងារនេះ មាននីតិវិធីក្នុងការស៊ើបអង្កេត ទៅលើពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ។ លោកអ្នកមានសិទ្ធិសរសេរបរិយាយអំពីនីតិវិធីនេះ។ ភ្នាក់ងារនេះ អាចដឹងក្រោយពេលស៊ើបអង្កេតថា មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីពាក្យបណ្តឹង របស់លោកអ្នក។ ថ្វីបើមានករណីបែបនេះក្តី លោកអ្នកមានសិទ្ធិដាក់ពាក្យបណ្តឹង និងស្នើរអោយមានការស៊ើបអង្កេត ប្រសិនបើលោកអ្នកជឿថា មន្រ្តីនគរបាល ពិតជាបានធ្វើអ្វីមួយមិនត្រឹមត្រូវមែន។ ភ្នាក់ងារត្រូវតែរក្សាទុកពាក្យបណ្តឹង និងរបាយការណ៍ណាមួយ របស់ប្រជាពលរដ្ឋ ឬការរកឃើញណាមួយ ទាក់ទងនឹងពាក្យបណ្តឹង យ៉ាងហោចណាស់ ឱ្យបានរយៈពេលប្រាំឆ្នាំ ។

# នាយកដ្ឋានស្នងការនគរបាល
# SIGNAL HILL

# ព័ត៌មានទាក់ទងនឹងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ


2745 វិថី Walnut

Signal Hill, លេខកូដ CA 90755

(562) 989-7205

# សារពីប្រធានស្នងការនគរបាល

ជូនចំពោះប្រជាពលរដ្ឋ ជាទីនឹករឭកៈ

គោលការណ៍ដ៏សំខាន់បំផុត របស់នាយកដ្ឋានយើងខ្ញុំ គឺដើម្បីស្វែង យល់ និងទទួលដឹងថា វិជ្ជាជីវៈរបស់យើងខ្ញុំមានពាក់ព័ន្ធនឹងការធ្វើការជាមួយសាធារណៈជន ហើយយើងខ្ញុំបង្ហាញពភាពខ្លាំងបំផុត នៅពេលយើង បម្រើប្រជាពលរដ្ឋ ដោយមានការគោរព ការយោគយល់ និងសេចក្តីថ្លៃថ្នូរ ដូចមានបង្ហាញនៅក្នុងសេចក្តីថ្លែង នៃគុណតម្លៃ របស់យើងខ្ញុំ។

បុគ្គលិកទាំងអស់ទទួលស្គាល់ និងពេញចិត្តចំពោះការទទួលខុសត្រូវ ក្នុងការបម្រើសហគមន៍ របស់យើង ដោយដឹងគ្រប់ពេលថា យើងខ្ញុំជាអ្នកថែទាំសង្គមដ៏ប្រណិត និងសំខាន់នេះ ដែលប្រជាជនផ្តល់ក្តីទុកចិត្តអោយ។ យើងខ្ញុំដឹងថាសហគមន៍រំពឹងមកលើយើងខ្ញុំ ក្នុងការផ្តល់ជូនសេវា ប្រកបដោយវិជ្ជាជីវៈ និងគួរជាទីពឹងអាស្រ័យបាន ដោយក្នុងនោះរួមមាន ការការពារប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិ, ការចាប់ខ្លួនជនបំពានច្បាប់ និងការធ្វើអ្វីៗ គ្រប់យ៉ាងដែល យើងខ្ញុំអាចធ្វើទៅបាន ដើម្បីលើកកម្ពស់យុត្តិធម៌។

នាយកដ្ឋានស្នងការនគរបាល Signal Hill មិនអត់អោន ឬផ្តល់ជាលេសយករួចខ្លួនជាដាច់ខាត ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវណាមួយរបស់នគរបាល។ ការស៊ើបអង្កេតយ៉ាងពេញលេញមួយនឹងត្រូវធ្វើឡើងសម្រាប់រាល់ពាក្យបណ្តឹង ជាផ្លូវការទាំងឡាយ ។

Christopher M. Nunley
ស្នងការនគរបាល

**ក្តីបារម្ភ ឬសំណួរផ្សេងៗ ៖**
ប្រសិនលោកអ្នក មានសំណួរ ឬក្តីបារម្ភណាមួយ អំពីការប្រតិបត្តិរបស់មន្ត្រីនគរបាល របស់នាយកដ្ឋានស្នងការនគរបាល Signal Hill សូមស្នើសុំដើម្បីនិយាយជាមួយមេបញ្ជាការត្រួតពិនិត្យ ដែលកំពុងបំពេញការងារ។ ជារឿយៗ មេបញ្ជាការត្រួតពិនិត្យ អាចឆ្លើយបានរាល់សំណួរអំពីគោលការណ៍ និងនីតិវិធីនានាដែលអាចផ្តល់ ជាការយល់ដឹងប្រសើរឡើង អំពីសកម្មភាពដែល មន្ត្រីនគរបាល បានប្រតិបត្តិ។

**ចំណុចផ្សេងៗ ទៀតដែ លខ្ញុំត្រូវដឹង ៖**
នាយកដ្ឋានស្នងការនគរបាល Signal Hill មាន បំណងរក្សាឱ្យបាននូវសេក្តីទៀងត្រង់របស់ខ្លួន និងមន្ត្រីរបស់ខ្លួន។ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋ និងមន្ត្រីនគរបាលនូវកិច្ចការពារ ក្នុងពេលធ្វើការពិនិត្យ-ផ្ទៀងផ្ទាត់, នោះការទាក់ទងជាមួយប្រជាពលរដ្ឋភាគច្រើន គឺត្រូវបានថតទុក ជាវីដេអូ និងសម្លេង។ ប្រសិនបើលោកអ្នកធ្វើសេចក្តីរាយការណ៍អំពីអ្វី ដែលលោកអ្នកជឿថា នគរបាលបានប្រព្រឹត្តខុស យើងខ្ញុំនឹងធ្វើការស៊ើបអង្កេតយ៉ាងហ្មតចត់ ហើយចាត់វិធានការណ៍យ៉ាងសមស្រប។

**ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ**

**អ្នកដែល អាចដាក់ពាក្យពាក្យបណ្តឹងបាន ៖**
ប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់វ័យ ឬមានសញ្ជាតិ ឬអត់នោះទេ សុទ្ធតែអាចដាក់ពាក្យបណ្តឹងបានដូចគ្នា។ ប្រសិនបើលោកអ្នកមានអាយុក្រោម 18 ឆ្នាំ លោកអ្នកគួរនាំឪពុកម្តាយ ឬអាណាព្យាបាល មកជាមួយ នៅពេលដាក់ពាក្យបណ្តឹង។

**របៀបដែលខ្ញុំអាចដាក់ពាក្យបណ្តឹងបាន ៖**
លោកអ្នកអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ តាមរយៈទូរស័ព្ទឬអ៊ីម៉ែល។ ក្នុងគ្រប់ករណីទាំងអស់ ពាក្យបណ្តឹងរបស់លោកអ្នក នឹងត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់។ ដោយសារការស៊ើបអង្កេត តាមពាក្យបណ្តឹងទាំងអស់ ត្រូវរៀបចំមកជាការសរសេរវិញ។ វាជាការប្រសើរប្រសិន បើលោកអ្នកសរសេរពីរាល់ការពិត ដែលលោកអ្នកដឹង។កំហុសឆ្គងនឹងមិនងាយកើតមានឡើងនោះទេ ចំពោះការធ្វើបែបនេះ។ ប្រសិនបើលោកអ្នកមានការលំបាក ក្នុងការសរសេរ មេបញ្ជាការត្រួតពិនិត្យ នឹងផ្តល់ជំនួយដល់លោកអ្នកបាន។

**អ្នកដែលខ្ញុំគួរដាក់ពាក្យបណ្តឹង ជូនទៅ ៖**
គ្រប់មន្ត្រីនៅនាយកដ្ឋានស្នងការនគរបាល ត្រូវបានតម្រូវដោយគោលនយោបាយ ឱ្យទទួលយកពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ។ ដោយសារពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ត្រូវបានចាត់ទុកជាបញ្ហាធ្ងន់ធ្ងរមួយ លោកអ្នកគួរស្នើសុំជួប ឬនិយាយជាមួយមេបញ្ជាការត្រួតពិនិត្យ។ ប្រសិនលោកអ្នកសម្រេចដាក់ពាក្យបណ្តឹង ទៅកាន់មន្ត្រីណាមួយផ្សេងទៀត សូមកុំព្រួយបារម្ភ ប្រសិនលោកអ្នកត្រូវបានស្នើសុំឱ្យរង់ចាំ ខណៈដែលមេបញ្ជាការត្រួតពិនិត្យ ត្រូវបានជូនដំណឹងនោះ។ ពាក្យបណ្តឹងរបស់លោកអ្នកមានសារៈសំខាន់ ហើយវិធានរបស់យើងខ្ញុំតម្រូវថា មេបញ្ជាការ ត្រួតពិនិត្យនោះត្រូវទទួលបានការជូនព័ត៌មាន ។

**របៀប ដែលពាក្យបណ្តឹងរបស់ខ្ញុំ ត្រូវបានចាត់ចែង ៖**
ស្នងការនគរបាលនឹងត្រូវទទួលបានដំណឹង សំរាប់រាល់ពាក្យបណ្តឹងទាំងអស់ របស់ប្រជាពលរដ្ឋ។ ស្នងការនឹងធ្វើឱ្យប្រាកដថាការស៊ើអង្កេតដ៏ពេញលេញមួយ ត្រូវបានធ្វើឡើង ។ លោកអ្នកនឹងត្រូវបាន ផ្តល់ជូននូវច្បាប់ចម្លងនៃពាក្យបណ្តឹងដែលលោកអ្នកបានដាក់ នៅពេលដែលលោកអ្នកបានដាក់វារួចរាល់។ ច្បាប់រដ្ឋតម្រូវថា លោកអ្នកត្រូវបានការជូនដំណឹងអំពីលទ្ធផលនៃការស៊ើបអង្កេត ក្នុងរយៈពេល 30 ថ្ងៃ ក្រោយពេលបញ្ចប់ការងារស៊ើបអង្កេតរួច ។

**បែបបទពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ**
ដើម្បីដាក់ពាក្យបណ្តឹង ប្រឆាំងនឹងមន្ត្រីរបស់នាយកដ្ឋានស្នងការនគរបាល, សូមបំពេញព័ត៌មាន ដែលត្រូវបានស្នើសុំ នៅលើកម្រងសំណួរស្តីពីពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ។ សូមអរគុណ។